ប៉ុណ្ណោះ ដែលមានបន្ទិលសង្ស័យអំពីប្រធានបទ ហើយបានសួរថា តើអ្នកសម្ភាសន៍មកពីគណបក្សនយោបាយណែនឬទេ។ អ្នកផ្តល់ការសម្ភាសន៍តិចតួចប៉ុណ្ណោះ ដែលមានអារម្មណ៍មិនស្រួលនៅពេលចាប់ផ្តើមនិយាយដំបូង ប៉ុន្តែពួកគាត់បានទទួលនូវទំនុកចិត្តយ៉ាងឆាប់រហ័សក្នុងកំឡុងពេលសម្ភាសន៍ ដោយពួកគាត់មានអារម្មណ៍ថា អ្នកធ្វើការសម្ភាសន៍គោរពពួកគាត់ ។

ក្រុមការងារស្ងួលរីករាយ និងពេញចិត្តចំពោះអ្នកផ្តល់ការសម្ភាសន៍ ដែលបានចែករំលែកនូវបទពិសោធន៍ដ៏ជូរចត់របស់ពួកគាត់ ។ ការនេះ ធ្វើឱ្យយើងមានចម្ងល់កាន់តែច្រើន ហើយចង់ដឹងថែមទៀត ។ យើងក៏បានពិចារណាច្រើនផងដែរអំពីបទពិសោធន៍នៃសមាជិកគ្រួសាររបស់យើងដែលយើងមិនធ្លាប់បានដឹងពីមុនមក ។

បន្ទាប់ពីនោះទៀត យើងសោកស្តាយ និងមានអារម្មណ៍តក់ស្លុតចំពោះរឿងរ៉ាវលំបាកទាំងឡាយដែលយើងបានស្តាប់ឮដោយផ្ទាល់ពីអ្នកនៅរស់ទាំងអស់ ជាលើកដំបូងក្នុងជីវិតរបស់យើង ។ ជួនកាល អ្នកផ្តល់ការសម្ភាសន៍ យំ និងត្រូវការការយកចិត្តទុកដាក់ពីអ្នកធ្វើការសម្ភាសន៍ ។ នេះគឺជា បញ្ហាប្រឈមផ្ទាល់ខ្លួនសំរាប់អ្នកធ្វើការសម្ភាសន៍ទាំងអស់ ។ ប៉ុន្តែអារម្មណ៍ដែលនៅសេសសល់គឺជាទំនុកចិត្តលើខ្លួនឯងរបស់ក្រុមការងារស្ងួលក្នុងការនិយាយដោយស្មោះត្រង់ជាមួយប្រជាពលរដ្ឋ អំពីរបបខ្មែរក្រហម និងមានអារម្មណ៍ជ្រះថ្លាក្នុងការសួរនូវសំណួរបែបសិទ្ធស្នាល ។

យើងបានរៀនសូត្រ ដើម្បីទំនាក់ទំនង និងសម្របខ្លួនទៅតាមបុគ្គលិកលក្ខណៈបុគ្គលខុសៗគ្នា ។

## III. លទ្ធផលចំបងបំផុតនៃការស្ទាបស្ទង់មតិ:

តាមទស្សនៈរបស់វិទ្យាស្ថាន **លទ្ធផលដ៏សំខាន់បំផុត**ដែលទទួលបានពីការស្រាវជ្រាវនេះមានដូចខាងក្រោម:




៧៦,៩% នៃអ្នកផ្តល់ការសម្ភាសន៍នៅតែគិតអំពីអតីតកាល ពីព្រោះពួកគាត់នៅតែខឹងនឹងអ្វីដែលបានកើតឡើងដល់ពួកគាត់ ។ ៨៨,៦%ឆ្ងល់ថា តើហេតុអ្វីបានជាពួកគាត់ត្រូវឆ្លងកាត់នូវបទពិសោធន៍ដ៏អាក្រក់នោះ ហើយ៩២,៧% នៃអ្នកឆ្លើយសំណួរនៅតែមានអារម្មណ៍ភ័យខ្លាច[៣] ។

[៣] គួរកត់សំគាល់ថា សំណួរនីមួយៗអាចមានចំលើយច្រើនឱ្យជ្រើសរើស ដូច្នេះផលបូកនៃភាគរយមិនស្មើនឹង ១០០%ជានិច្ចនោះទេ ។

អ្នកឆ្លើយសំណួរមិនថាស្រី ឬប្រុស មិនមានឥទ្ធិពលថា តើពួកគេនៅគិតអំពីអតីតកាល ឬក៏អត់ទេ : ៨៧,៩%នៃស្ត្រី និង៩០,១%នៃបុរសនៅតែគិតអំពីអតីតកាល ។

បើយើងប្រៀបធៀបជាមួយលទ្ធផលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឆ្នាំ ២០០២ ចំនួនអ្នកឆ្លើយសំណួរ ដែលនៅតែគិតអំពីអតីតកាលបានកើនឡើងយ៉ាងខ្លាំង (នៅក្នុងឆ្នាំ២០០២ មានតែ៥៨,៧៥% "ប៉ុណ្ណោះ" នៅតែគិតអំពីអតីតកាល) ដែលបច្ចុប្បន្នមានរហូតដល់ទៅ ៨៩,១% ។

ការពិភាក្សាដែលកំពុងតែប្រព្រឹត្តទៅស្តីអំពីការកាត់ទោសពួកខ្មែរក្រហមអាចជាហេតុផលសំរាប់ការកើនឡើងនេះ ដែលរំលឹកអ្នកដែលនៅរស់ឱ្យនឹកឃើញដល់បទពិសោធន៍ដ៏អាក្រក់របស់ពួកគាត់ ។

**២. ៩៦,៨%នៃអ្នកឆ្លើយសំណួរចង់ឱ្យមានការកាត់ទោសពួកខ្មែរក្រហម ។**

ស្ត្រី (៩៧,៥%) និងបុរស (៩៦,២%) ចង់ឱ្យមានការកាត់ទោសក្រុមខ្មែរក្រហមដូចគ្នា ។

នៅក្នុងការស្ទង់មតិរបស់ "មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម" នៅក្នុងឆ្នាំ ២០០០ បានរកឃើញថា ៨២% នៃអ្នកឆ្លើយសំណួរចង់ឱ្យមានការកាត់ទោសខ្មែរក្រហម ។

ពីរឆ្នាំក្រោយមកនៅក្នុងឆ្នាំ ២០០២ ចំនួននេះបានថយចុះ ១០% មកនៅត្រឹម ៧២% នៅពេលដែលអ្នកឆ្លើយសំណួរនៅក្នុងការស្ទាបស្ទង់មតិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានឆ្លើយថា ពួកគាត់ចង់ឃើញគេបង្កើត "តុលាការកាត់ទោសខ្មែរក្រហម" ឱ្យបានឆាប់ ។

ទាំងនេះបញ្ជាក់ច្បាស់ថា ភាគច្រើននៃអ្នកផ្តល់ការសម្ភាសន៍ចង់ឱ្យមានតុលាការកាត់ទោសខ្មែរក្រហម ។

**កំរិតសិក្សារបស់អ្នកផ្តល់ការសម្ភាន៍** មិនមានឥទ្ធិពលលើ បំណងប្រាថ្នាចង់ឱ្យមានតុលាការកាត់ទោសខ្មែរក្រហម របស់ពួកគាត់ទេ ។ កំរិតវប្បធម៌ត្រូវបានបែងចែកដូចខាងក្រោម:

- មិនបានសិក្សា/សិក្សាបានតិច: មិនបានចូលរៀន និងកំរិតបឋមសិក្សា
- កំរិតសិក្សាមធ្យម: អនុវិទ្យាល័យ វិទ្យាល័យ និងសាលាបច្ចេកទេស/មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
- កំរិតសិក្សាខ្ពស់: សាកលវិទ្យាល័យ និងការសិក្សាក្រោយឧត្តមសិក្សា

ក្រាហ្វិកបង្ហាញថា ភាគច្រើនលើសលប់នៃអ្នកផ្តល់ការសម្ភាសន៍ដែលបានសិក្សា/សិក្សាបានតិច កំរិតសិក្សា-មធ្យម និងកំរិតសិក្សាខ្ពស់ចង់ឱ្យមានការកាត់ទោសខ្មែរក្រហម ។




សំគាល់: ១៨ នៃមនុស្សចំនួន ៥៣៦នាក់ (=៣,៨%) មិនបានឆ្លើយគ្រប់សំនួរនីមួយៗនោះទេ

**ទីលំនៅ**របស់ផ្ដល់ការសម្ភាសន៍ មិនមានឥទ្ធិពលលើបំណងប្រាថ្នាចង់បានការកាត់ទោសរបស់ពួកគេឡើយ ។ អ្នកផ្ដល់ការសម្ភាសន៍ទាំងនៅទីប្រជុំជន និងតំបន់ដាច់ស្រយាល ប្រាថ្នាចង់បានការកាត់ទោសដូចគ្នា ។




៦១,៣%នៃអ្នកផ្ដល់ការសម្ភាសន៍របស់យើងរំពឹងថា ការកាត់ទោសនឹងនាំមកនូវយុត្តិធម៌ ។

២២,៩% មិនយល់ស្រប ហើយគិតថា នឹងមិននាំមកនូវយុត្តិធម៌ទេ ។

តែ៧,៦%ប៉ុណ្ណោះនិយាយថា ការកាត់ទោសនឹងនាំមកនូវភាពចំរូងចំរាស់ជាថ្មី ។ វាជាគួរឱ្យភ្ញាក់ផ្អើលដែលក្នុងចំណោម ផ្ដល់ការសម្ភាសន៍ទាំងនេះ ភាគច្រើនបំផុតមិនមានការភ័យខ្លាចទេ (ដូចគេអាចសន្និដ្ឋាន) ប៉ុន្តែមានការសោកស្ដាយ (៧២,៥%) ឬខឹងសប្បារ (៧៧,៥%) នៅពេលដែលពួកគាត់ និយាយអំពីរឿងអតីតកាល ។

**៣. ២៤,៦% នៃអ្នកផ្ដល់ការសម្ភាសន៍ដែលមិនបានដឹងថាការកាត់ទោសខ្មែរក្រហមនឹងត្រូវបានបង្កើតឡើង** នៅពេលអនាគតដ៏ឆាប់ខាងមុខ ទោះបីជាការចរចារវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងបានប្រព្រឹត្តទៅអស់រយៈពេលយ៉ាងតិចប្រាំឆ្នាំកន្លងមកក៏ដោយ ។

ក្នុងចំណោមអ្នកផ្ដល់ការសម្ភាសន៍ ២៤,៦%នេះ មាន **៧៣,៣%** **ជាស្ត្រី** និង **២៦,៧%** **ជាបុរស** ។

៤. លទ្ធផលដ៏គួរឱ្យចាប់អារម្មណ៍នោះគឺ **ស្ទើរតែពាក់កណ្ដាលនៃអ្នកចូលរួម (៤៤,១%) ពេញចិត្តមិនឱ្យមានការកាត់ទោស ជាងមានការកាត់ទោសដែលមិនយុត្តិធម៌១០០%** ។




នោះមានន័យថា អ្នកផ្ដល់ការសម្ភាសន៍ជាច្រើនដឹងច្បាស់ថា ស្ដង់ដារយុត្តិធម៌ក៏រិតទីពីរនៃសាលាក្ដីកាត់ទោសខ្មែរក្រហម អាចមានផលវិបាកធ្ងន់ធ្ងររយៈពេលយូរ ដល់បញ្ហាដែលកំពុងកើតមានដែលពាក់ព័ន្ធនឹងនីតិរដ្ឋរបស់ប្រទេស។